# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទរាជរដ្ឋាភិបាលខ្មែរ គប្បីប្រុងប្រយ័ត្នអំពីការបាត់បង់ទឹកដីខ្មែរ និងអំពីអន្តោប្រវេសន៍វៀតណាមចូលមកកម្ពុជាខុសច្បាប់កាន់តែច្រើនឡើងៗ

web site: hoksavann.org

ថ្ងៃទី២៨ កក្កដា ២០០៦

បន្ទាប់អំពីសន្ធិសញ្ញាបំពេញបន្ថែមបានត្រូវធ្វើសច្ចានុម័ត និងចុះហត្ថលេខាដោយព្រះមហាក្សត្រសីហមុនីមក រាជរដ្ឋាភិបាលខ្មែរនិងវៀតណាមបានព្រមព្រៀងគ្នាថា នឹងបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរឲ្យរួចរាល់ក្នុងឆ្នាំ២០០៨ ។ តើការបោះបង្គោលព្រំដែននោះមានយុត្តិធម៌ឬទេ, បើតាមរាជរដ្ឋាភិបាលខ្មែរថាខ្មែរមិនបាត់បង់ទឹកដីទេ តែបើតាមអ្នកជំទាស់ថា ខ្មែរមានបាត់បង់ទឹកដី ព្រោះការចុះហត្ថលេខាអំឡុងឆ្នាំ១៩៨០នោះ មានភាពពុំស្មើគ្នា រវាងវៀតណាមនិងកម្ពុជា គឺវៀតណាមត្រួតត្រាលើប្រទេសកម្ពុជាដោយកម្លាំងទ័ព , តាមកិច្ចព្រមព្រៀងអន្តរជាតិនៅទីក្រុងប៉ារីសឆ្នាំ១៩៩១ ស្តីអំពីសន្តិភាពប្រទេសកម្ពុជាបានចែងថា សន្ធិសញ្ញាខុសច្បាប់ទាំងឡាយ ដែលចុះហត្ថលេខាក្នុងអំឡុងពេល ដែលវៀតណាមបានចូលកាន់កាប់ប្រទេសកម្ពុជា ត្រូវលុបចោលឬទុកជាមោឃៈ ។ មិនត្រឹមតែមិនលុបចោលទេ ថែមទាំងរាជរដ្ឋាភិបាលចាប់អ្នកដែលប្រឆាំងនឹងសន្ធិសញ្ញាខុសច្បាប់នោះដាក់គុកទៀតផង ហើយត្រូវដោះលែងវិញ ពេលដែលសន្ធិសញ្ញាបំពេញបន្ថែមនោះបានសំរេច ។ នេះបញ្ជាក់ថា វត្ថុបំណងយ៉ាងណា រាជរដ្ឋាភិបាលខ្មែរត្រូវតែបំពេញនោះឲ្យបានសំរេច រហូតចាប់អ្នកស្នេហាទឹកដី គ្រាន់តែបញ្ចេញយោបល់ សំដែងការព្រួយបារម្ភអំពីការបាត់បង់ទឹកដីរបស់ខ្លួនដាក់គុកថែមទៀត ។ នេះជាការរំលោភសិទ្ធិបញ្ចេញយោបល់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ននិងសន្ធិសញ្ញាអន្តរជាតិរបស់រាជរដ្ឋាភិបាលខ្មែរ ដែលត្រូវថ្កោលទោសពេញពិភពលោក ។ បើរាជរដ្ឋាភិបាលខ្មែរតំណាងផលប្រយោជន៍ខ្មែរ ត្រូវតែប្រមូលយោបល់របស់ខ្មែរអ្នកស្នេហាជាតិទាំងអស់មកដោះស្រាយបញ្ហាជាតិ ជាពិសេសបញ្ហាទឹកដីនេះ ។ កុំយកចិត្តបរទេ

សជ្រុលពេក រហូតប្រឆាំងនឹងឆន្ទៈប្រជាពលរដ្ឋរបស់ខ្លួន ។ អំណាចដែលកើតចេញពីប្រជាពលរដ្ឋ ការពារទើបស្ថិតស្ថេរ ឯអំណោចកើតចេញពីបរទេស ការពារពុំស្ថិតស្ថេរឡើយ ដូច្នេះត្រូវបំរើផលប្រយោជន៍ប្រជាពលរដ្ឋ ត្រូវយកចិត្តប្រជាពលរដ្ឋ ដើម្បីឲ្យប្រជាពលរដ្ឋការពារអំណាច កុំយកចិត្តបរទេសរហូតបាត់បង់ទឹកដី ។ ក្នុងន័យនេះ សូមរាជរដ្ឋាភិបាលពិនិត្យឡើងវិញ នូវបង្គោលសីមាដែលបានបោះក្នុងអំឡុងឆ្នាំ១៩៨០ កុំឲ្យខ្មែរបាត់បង់ទឹកដី ព្រោះជនជាតិខ្មែរទូទៅមិនជឿថា ខ្មែរមិនបាត់បង់ទឹកដីរបស់ខ្លួនឡើយ ជាពិសេសប្រជាពលរដ្ឋខ្មែរនៅតាមព្រំប្រទល់ដែនតែងតែស្រែកប្រាប់អ្នកយកពត៌មានថា យួនលួចបង្ខិតបង្គោលសីមា យួនបានប្លន់យកដីស្រែរបស់ខ្លួនជាដើម ។ នេះជាសក្ខីភាពមួយដែលបញ្ជាក់ថា ការព្រួយបារម្ភនោះ ជាការត្រឹមត្រូវ ។ មួយទៀត កុំយកផែនទីដែលយួនតម្រូវឲ្យយក តែត្រូវយកផែនទីដែលអន្តរជាតិទទួលស្គាល់ ហើយអ្នកជំនាញការខ្មែរអំពីព្រំដែនយល់ថា ជាផែនទីត្រឹមត្រូវ ។ បើពិនិត្យទៅឃើញថា បង្គោលសីមាដែលបោះក្នុងអំឡុងឆ្នាំ១៩៨០ នាំឲ្យខ្មែរខាតបង់ដី ត្រូវតែសើរើឡើងវិញ មុននឹងបោះបង្គោលជាបន្តទៅទៀត ។ ផែនការដែលវៀតណាមបោះបង្គោលសីមាព្រំដែនរវាងខ្មែរនិងវៀតណាម ឲ្យចប់សព្វគ្រប់នៅឆ្នាំ២០០៨នោះ ព្រោះផុតពីឆ្នាំ២០០៨ទៅជាអាណត្តិថ្មីរបស់រាជរដ្ឋាភិបាលខ្មែរ វៀតណាមមានការព្រួយបារម្ភថា អាណត្តិថ្មីនេះ មិនដឹងជារាជរដ្ឋាភិបាលខ្មែរ មានទ្រង់ទ្រាយនិងមានកម្មវិធីនយោបាយបែបណាទេចំពោះខ្លួន ។ ចំណែករាជរដ្ឋាភិបាលខ្មែរសព្វថ្ងៃនេះជាកូនចៅរបស់ខ្លួន តាំងពីឆ្នាំ១៩៧៩មក ប្រើបានការប្រើឲ្យធ្វើអ្វីមិនប្រកែកតែងតែធ្វើតាមភ្លាម ដូចជាបង្គាប់ឲ្យធ្វើសន្ធិសញ្ញាបំពេញបន្ថែម ឲ្យស្របច្បាប់ នូវសន្ធិសញ្ញាមិនស្របច្បាប់ឆ្នាំ១៩៨៥ជាដើម ។ រាជរដ្ឋាភិបាលខ្មែរធ្វើតាមវៀតណាមរហូតចាប់អ្នកប្រឆាំងនឹងសន្ធិសញ្ញាខុសច្បាប់ឆ្នាំ១៩៨៥ ហើយបញ្ចុះបញ្ចូលព្រះមហាក្សត្រ ឲ្យចុះព្រះហត្ថលេខាទៀតផង ។ មិនដែលឃើញប្រទេសក្នុងពិភពលោក ដែលប្រជាពលរដ្ឋរបស់ខ្លួនបញ្ចេញយោបល់ការពារទឹកដីរបស់ខ្លួន បែរជារាជរដ្ឋាភិបាលចាប់ដាក់គុក ដូចជារាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ននេះឡើយ ។ តាមសក្ខីភាពនេះ តើគេអាចចោទថា រាជរដ្ឋាភិបាលសព្វថ្ងៃនេះពុំមែនបំរើផលប្រយោជន៍ខ្មែរទេក្នុងបញ្ហាទឹកដីនេះ គឺបំរើផលប្រយោជន៍វៀតណាម ការពារផលប្រយោជន៍វៀតណាម បានជាប្រឆាំងនឹងប្រជាពលរដ្ឋខ្មែរ ដែលបំរើផលប្រយោជន៍ជាតិខ្លួន ។ វៀតណាមជាអ្នកមានគុណ ការពារអំណាចឲ្យខ្លួន ដូច្នេះត្រូវតែដឹងគុណវៀតណាម ទោះបីបាត់បង់ទឹកដីខ្លះក៏ដោយ ។ ទឹកដីប្រទេសកម្ពុជា ជាកម្មសិទ្ធិរបស់ខ្មែរទាំងអស់គ្នា ពុំអាចជនណាយកទៅលក់ដូរបានឡើយ ហើយក៏មិនមែនជាទឹកដីរបស់រាជរដ្ឋាភិបាលខ្មែរប៉ុន្មាននាក់នោះទេ ទោះបីរាជរដ្ឋាភិបាលខ្មែរជាអ្នកទទួលខុសត្រូវក៏ដោយ ក៏ត្រូវតែមានការចូលរួមបញ្ចេញមតិពីប្រជាជនទូទៅ ព្រោះបញ្ហាទឹកដីនេះ ជាបញ្ហាធំជាងអាយុជីវិតរបស់ប្រទេសជាតិ ។ បញ្ហារបស់ជាតិខ្លះ រា

ជរដ្ឋាភិបាលមិនអាចអារកាត់ ត្រូវបញ្ជូនទៅរដ្ឋសភា ព្រឹទ្ធសភា បើស្ថាប័នទាំងពីរនេះពុំអាចដោះស្រាយបានទៀត គេត្រូវធ្វើប្រជាមតិ ឲ្យប្រជាពលរដ្ឋអារកាត់ ។ ព្រឹត្តិការណ៍កន្លងមក រាជរដ្ឋាភិបាលចាប់ប្រជាពលរដ្ឋដាក់គុក ដោយគ្រាន់តែសំដែងការព្រួយបារម្ភអំពីទឹកដីរបស់ខ្លួន អំពើនេះជាការខុសឆ្គងខ្លាំងណាស់ ជាអំពើផ្តាច់ការ រាជរដ្ឋាភិបាលខ្មែរត្រូវតែបញ្ឈប់អំពើខុសឆ្គងបែបនេះ កុំអនុវត្តតទៅទៀត បើចង់ឲ្យប្រទេសកម្ពុជាជាប្រទេសគោរពច្បាប់ ។ បើយល់ស្របតាមឧត្តមគតិនេះហើយ ត្រូវតែបើកឲ្យអ្នកជំនាញការខាងព្រំដែនក្រៅរដ្ឋាភិបាល ចូលរួមជាមួយអ្នកជំនាញការរបស់រាជរដ្ឋាភិបាល ធ្វើការរួមគ្នាពិនិត្យមើលបង្គោលព្រំដែន ដែលបានបោះរួចហើយអំឡុងឆ្នាំ១៩៨០ តើត្រឹមត្រូវឬមិនត្រឹមត្រូវ បើមិនត្រឹមត្រូវទេ ដាច់ខាតត្រូវតែសើរើឡើងវិញ មុននឹងបោះបន្ត ។ ភស្តុតាងបញ្ជាក់ឲ្យយើងឃើញថា វៀតណាមពិតជាចំណេញទឹកដី បានជាគេបង្ខំឲ្យរាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្នដែលជាកូនចៅរបស់គេធ្វើកិច្ចការបោះបង្គោលព្រំដែននេះ ឲ្យរួចស្រេចក្នុងឆ្នាំ២០០៨ ព្រោះខ្លាចរាជរដ្ឋាភិបាលថ្មីសើរើ ឬលុបសន្ធិសញ្ញាបំពេញបន្ថែមនេះ ការចំណេញនេះនឹងត្រូវបាត់បង់ទៅវិញ ។ តើរាជរដ្ឋាភិបាលមានបង់ខាតអ្វី បើឲ្យអ្នកជំនាញការគ្រប់អង្គការក្រៅរដ្ឋាភិបាលចូលរួមធ្វើការជាមួយ តាមពិតចំណេញទៅវិញទេ គឺចំណេញត្រង់អស់អ្នកប្រឆាំង ហើយបើគេចោទរាជរដ្ឋាភិបាល នឹងបានអង្គការដែលចូលរួមនោះជាសាក្សីជួយការពារ ហើយបានប្រយោជន៍ជាពិសេស គឺខ្មែរមិនបាត់បង់ទឹកដី ។ សំណើនេះសមហេតុសមផល គួររាជរដ្ឋាភិបាលទទួលយកបាន ។ បានសេចក្តីថា បញ្ហាទឹកដីជាបញ្ហាធំណាស់ រាជរដ្ឋាភិបាលនិងអ្នកជំនាញការរបស់ប្រជាពលរដ្ឋធ្វើសហការគ្នា ដើម្បីការពារទឹកដីរបស់ខ្លួន ។ រាជរដ្ឋាភិបាលបានប្រកាន់ថា យើងជារាជរដ្ឋាភិបាលតំណាងប្រជាពលរដ្ឋ ហើយមិនចាំបាច់មានប្រជាពលរដ្ឋក្រុមណាមួយធ្វើការរួមទៀតទេ ។ ការប្រកាន់ដូចនេះត្រឹមត្រូវហើយ ប៉ុន្តែកាលៈទេសៈនេះមានលក្ខណៈពុំប្រក្រតី ព្រោះប្រជាពលរដ្ឋខ្មែរជាទូទៅពុំជឿទុកចិត្តលើរាជរដ្ឋាភិបាលបច្ចុប្បន្ននេះ ព្រោះគេដឹងគ្រប់គ្នាថា ជារាជរដ្ឋាភិបាលមានវៀតណាមនៅពីក្រោយ ។ ដូច្នេះបើធ្វើតាមរូបមន្តខាងលើ អាចបង្កើតការទុកចិត្តរបស់ប្រជាពលរដ្ឋ អំពីបញ្ហាព្រំដែននេះមកលើរាជរដ្ឋាភិបាលវិញបានខ្លះ ។

ចំណែកព្រំដែនរវាងខ្មែរនិងថៃវិញ រាជរដ្ឋាភិបាលខ្មែរនិងថៃ ក៏មានគោលបំណងបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរ ឲ្យរួចរាល់បានឆាប់ដែរ ។ រាជរដ្ឋាភិបាលខ្មែរត្រូវទាញការប្រុងប្រយ័ត្នដូចគ្នា ព្រោះប្រទេសថៃក៏ធ្លាប់យកទឹកដីខ្មែរជាច្រើនខេត្តសម័យបូរាណ ហើយតាមសំដីរបស់ប្រជាពលរដ្ឋខ្មែរនៅតាមព្រំដែនថា ថៃបានបង្ខិតព្រំដែនចូលមកដីខ្មែរជាច្រើនកន្លែង ជាពិសេសសម័យខ្មែរមានសង្គ្រាមឆ្នាំ១៩៨០ ។ តាមសំដីរបស់ប្រជាពលរដ្ឋខ្មែរម្នាក់ពោលថា ព្រំដែនខ្មែរ-ថៃនៅខេត្តបន្ទាយមានជ័យ ពេលយប់ថៃបានជួលខ្មែរ៨០បាត ឲ្យជីកបង្គោលចាស់ចោល

ហើយយកមកដាំបង្គិតចូលដីខ្មែរយ៉ាងជ្រៅ ។ ពត៌មាននេះពិតឬមិនពិត គួររាជរដ្ឋាភិបាលយកចិត្តទុកដាក់ពិនិត្យមើលឲ្យបានហ្មត់ចត់ ។ ដូចគ្នាដែរ មុននឹងបោះបង្គោលបន្ត ត្រូវពិនិត្យមើលបង្គោលដែលមានហើយ តើបង្គោលនោះជាបង្គោលចាស់មានមកតាំងពីសម័យអាណានិគមនិយមបារាំងពិតប្រាកដ ដោយផ្ទៀងផ្ទាត់មើលតាមផែនទីដែលគួរទទួលយកបាន ឬជាបង្គោលថ្មី ឬជាបង្គោលចាស់មកដាំកន្លែងថ្មី ដែលថៃលួចដាំនិងលួចបង្គិតខុសពីកន្លែងចាស់ ។ អាចយកអ្នកបច្ចេកទេសខាងក្រៅរាជរដ្ឋាភិបាល ដែលចេះដឹងអំពីបញ្ហាព្រំដែនខ្មែរ-ថៃមកជាជំនួយ និងចាស់ទុំដែលដឹងអំពីព្រំដែនខ្មែរ-ថៃពីដើម ក្រោយមកថៃលួចបង្គិត ធ្វើជាសាក្សី ។ ចំណែកការបោះបង្គោលព្រំដែនរវាងខ្មែរនិងលាវ ក៏ត្រូវអនុវត្តដូចពោលមកហើយដូចគ្នា

<u>អំពីក្រសួងអន្តោប្រវេសន៍</u> ៖

គ្រប់ប្រទេសទាំងអស់ក្នុងលោក តែងតែបង្កើតក្រសួងអន្តោប្រវេសន៍ ដើម្បីពិនិត្យមើលអ្នកចូលក្នុងប្រទេសរបស់ខ្លួន ដោយស្របច្បាប់ឬមិនស្របច្បាប់ ។ តើហេតុអ្វីបានជារាជរដ្ឋាភិបាលខ្មែរមិនព្រមបង្កើតក្រសួងអន្តោប្រវេសន៍ និងអនុវត្តច្បាប់អន្តោប្រវេសន៍ឲ្យបានម៉ត់ចត់ ។ ការដែលយកក្រសួងមហាផ្ទៃមកបំពេញមុខងារ ជាក្រសួងអន្តោប្រវេសន៍ ពុំអាចបំពេញមុខងារនោះបានពេញលេញឡើយ ។ ក្រសួងអន្តោប្រវេសជាក្រសួងចាំបាច់ត្រូវតែបង្កើត ទោះបីត្រូវចំណាយថវិកាប៉ុន្មានក៏ដោយ ។ បណ្តាជនអន្តោប្រវេសន៍ទាំងអស់ ដែលខ្មែរចាប់អារម្មណ៍ អន្តោប្រវេ-សន៍វៀតណាមជាងគេ ។ ពុំមែនឥតហេតុផលនិងថាខ្មែរប្រកាន់ជាតិសាសន៍នោះទេ ។ តាំងពីកងទ័ពវៀតណាមចូលមកកាន់កាប់ប្រទេសកម្ពុជានៅឆ្នាំ១៩៧៩ ហើយប្រកាសដកទៅវិញនៅឆ្នាំ១៩៨៩ ។ យោធាវៀតណាមខ្លះមិនចេញទៅប្រទេសរប-ស់ខ្លួនវិញទេ បានផ្លាស់ខោអាវពីយោធាមកជាស៊ីវិល ហើយរស់នៅក្នុងប្រទេសកម្ពុជាជាមួយជនស៊ីវិលវៀតណាមជាច្រើនទៀត ។ ដូច្នេះជនជាតិវៀតណាមមួយជំពូកមករស់នៅប្រទេសកម្ពុជា ជាមួយកងទ័ពវៀតណាម ដែលចូលមកកាន់កាប់ប្រទេសកម្ពុជា ។ ជនជាតិវៀតណាមមួយជំពូកទៀត ធ្លាប់រស់នៅក្នុងប្រទេសកម្ពុជាជាយូរមកហើយ ដែលក្លាយទៅជាជនជាតិខ្មែរស្របច្បាប់ ។ ចំណែកជនជាតិវៀតណាមមួយជំពូកទៀត ទើបមករស់នៅប្រទេសកម្ពុជា ក្នុងពេលដែលប្រទេសកម្ពុជាមានសន្តិភាព ចាប់ពីឆ្នាំ១៩៩១មក ។ ប្រទេសកម្ពុជាជាប្រទេសគោរពព្រះពុទ្ធសាសនា ជាសាសនានិយមសន្តិភាព ដូច្នេះយើងចង់ឲ្យប្រទេសទាំងអស់ជាមិត្ត ជាពិ-សេសប្រទេសជិតខាងភូមិផងរបងជាមួយ ប៉ុន្តែសូមធ្វើសំណូមពរ សូមឲ្យប្រទេ-សទាំងអស់គោរពសិទ្ធិគ្នាទៅវិញទៅមក កុំរំលោភឈ្លានពានគ្នា ។ ការធ្វើសំណូមពរចង់ឲ្យមានក្រសួងអន្តោប្រវេសន៍នោះ គឺដើម្បីពិនិត្យមើលជនបរទេសទាំងអស់ដែលមកប្រទេសកម្ពុជា មានជនជាតិវៀតណាមជាដើម តើជនណាមកជាទេសចរមកធ្វើវិនិយោគទុន ជនណាមានសិទ្ធិរស់នៅប្រទេសកម្ពុជា និងជនដែលមិនមាន

សិទ្ធិ គឺត្រូវអនុវត្តស្របតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។ ជនជាតិខ្មែរមានការព្រួយបារម្ភនោះ គឺនៅត្រង់វៀតណាមចូលមកកម្ពុជាមានលក្ខណៈនយោបាយ ។ បានសេចក្តីថា បើវៀតណាមចូលមកកម្ពុជាកាន់តែច្រើនឡើងៗ ដោយគ្មានការត្រួតពិនិត្យទេ យូរទៅខ្មែរទៅជាជនជាតិភាគតិចនៅក្នុងប្រទេសកំណើតរបស់ខ្លួន ព្រោះប្រទេសវៀតណាមមានប្រជាជនជាង៧០លាននាក់ មានដីកាន់តែចង្អៀត ពិបាករស់នៅ ត្រូវតែមានចលនាមកទិសខាងលិច គឺមកប្រទេសកម្ពុជានេះឯង ។៚

❑ ❑

❑